**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧២. សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តមូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- សេចក្តីសម្រេចលេខ ២៧ ស.ស.រ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការកែសំរួលសេចក្តីសម្រេច ស្តីពីការបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការដឹកនាំការងារ ដើម្បីអភិវឌ្ឍផ្នែកឯកជន និងក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការ និងក្រុមការងារសម្រាប់អនុវត្តមូលនិធិពហុភាគី និងសម្របសម្រួលអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ហៅកាត់ថា "គណៈកម្មការមូលនិធិពហុភាគី" ដែលមានសមាសភាពមកពីក្រសួង ស្ថាប័នដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ផាន សូរស័ក្តិ** | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. | ឯកឧត្តម | **អ៊ិត ប្រាំង** | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | អនុប្រធាន |
| ៣. | ឯកឧត្តម | **គឹមរ៉េត សំរេច** | រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤. | ឯកឧត្តម | **គិត សេង** | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៥. | លោកជំទាវ | **ចំនួ ស៊ូរីយ៉** | រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| ៦. | ឯកឧត្តម | **ស្រ៊ុន តារា** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. | ឯកឧត្តម | **ឡោង ចនយុទ្ធា** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨. | លោកជំទាវ | **គឹម វ៉េតស៊ីង** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩. | ឯកឧត្តម | **មេង សុធី** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០. | ឯកឧត្តម | **ភាន ចំនួមេត្តា** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១. | ឯកឧត្តម | **ឯម សោភ័ណ្ឌ** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២. | ឯកឧត្តម | **ទិត ទីណា** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣. | ឯកឧត្តម | **គង់ កន្ធារ៉ា** | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៤. | ឯកឧត្តម | **ឱុយ ចៅ** | អគ្គលេខាធិការរងនៃគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១៥. | ឯកឧត្តម | **សុខ សុភ័ក្ត្រ** | អគ្គនាយកពាណិជ្ជកម្មអន្តរជាតិ ក្រសួងពាណិជ្ជកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ១៦. | ឯកឧត្តម | **ទិត ចន្ថា** | អគ្គនាយក ក្រសួងទេសចរណ៍ | សមាជិក |
| ១៧. | ឯកឧត្តម | **លី គឹមសុខ** | នាយកសាលាភូមិន្ទរដ្ឋបាល | សមាជិក |
| ១៨. | លោក | **គុណ ញឹម** | អគ្គនាយករងគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៩. | លោក | **អ៊ុច គឹមយ៉ុន** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ២០. | លោក | **ហង់ សុជីវិន** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិក្រសួងពាណិជ្ជកម្ម | លេខាធិការ ។ |

**ប្រការ ២.-**

គណៈកម្មការមូលនិធិពហុភាគី មានតួនាទីជួយអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម និងមានភារកិច្ចដូចខាងក្រោម :

ក) បង្កើតគម្រោង និងកម្មវិធីអភិវឌ្ឍន៍ដោយផ្អែកតាមសេចក្តីត្រូវការរបស់ក្រសួង ស្ថាប័ននីមួយៗ និងឱ្យស្របតាមគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ។

ខ) ពិនិត្យ រៀបចំ និងកែសម្រួលសូចនាករសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគម្រោងរបស់សេរសេរស្តម្ភ ។

គ) ណែនាំក្រុមការងាររបស់សសរស្តម្ភនីមួយៗ តាមកម្មវិធី ។

ឃ) ធានាមានការសម្របសម្រួលដ៏ល្អប្រសើរ និងគ្រប់ជ្រុងជ្រោយរវាងក្រសួង ស្ថាប័ននានា ក្នុងការអនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម ។

ង) អញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនឱ្យចូលរួមកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធ ដើម្បីផ្តល់យោបល់ក្នុងនាមជាអ្នកសង្កេតការណ៍ ។

ច) ដោះស្រាយបញ្ហានានា ដែលកើតឡើងពីការអនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម ។

ឆ) ពិនិត្យ សម្រេចលើសំណើរបស់ក្រុមការងារសសរស្តម្ភ ។

ជ) ពិនិត្យ វាយតម្លៃអំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាពនានារបស់កម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម ។

ឈ) ធានាឱ្យកិច្ចប្រតិបត្តិការនានាមានអនុលោមភាពតាមកម្មវត្ថុ តាមគោលការណ៍ និងតាមកម្មវិធីការងារប្រចាំឆ្នាំ ។

ញ) ពិនិត្យ និងបញ្ជូនរបាយការណ៍ស្តីពីវឌ្ឍនភាពការងារជូនទៅធនាគារពិភពលោក និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀតឱ្យបានជ្រាប បន្ទាប់ពីមានការអនុញ្ញាតពីអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម ។

ដ) សម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នទទួលនិងអនុវត្តជំនួយអភិវឌ្ឍន៍ពាណិជ្ជកម្មផ្សេងទៀតនៅក្រៅកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្មនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ។

ឋ) រៀបចំកម្មវិធីការងារប្រចាំឆ្នាំដាក់ជូនអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្មពិនិត្យ និងសម្រេច ។

ឌ) លើកសំណើស្តីពីការរៀបចំគម្រោងនៅក្នុងវិស័យផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍពាណិជ្ជកម្មដាក់ជូនក្រសួងពាក់ព័ន្ធពិនិត្យ និងសម្រេច ដើម្បីដាក់បញ្ចូលក្នុងគម្រោងអភិវឌ្ឍន៍របស់ក្រសួង ។ គម្រោងទាំងនោះរួមមាន ការពិនិត្យលើលទ្ធភាពនៃការធ្វើហិរញ្ញប្បទានផ្នែកពាណិជ្ជកម្ម ការបង្កើតធនាគារនាំចេញ នាំចូល និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងផ្នែកទុនដែលពាក់ព័ន្ធនឹងការអភិវឌ្ឍពាណិជ្ជកម្ម ។

ឍ) រៀបចំរបាយការណ៍ជូនទៅអនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម ដើម្បីពិនិត្យលើវឌ្ឍនភាពការងារ និងការធ្វើសេចក្តីសម្រេចលើកម្មវិធីការងារថ្មី ។

**ប្រការ ៣.-**

ត្រូវបានបង្កើតក្រុមការងារចំនួនបី សម្រាប់សសរស្តម្ភទាំងបី នៅក្រោមគណៈកម្មការអនុវត្តមូលនិធិពហុភាគី ដូចខាងក្រោម :

- ក្រុមការងារនីតិកម្ម និងបញ្ហាអន្តរវិស័យ
- ក្រុមការងារអភិវឌ្ឍន៍សេវាកម្ម និងផលិតផលសម្រាប់ការនាំចេញ
- ក្រុមការងារអភិវឌ្ឍន៍សមត្ថភាពពាណិជ្ជកម្ម ។

គណៈកម្មការអនុវត្តន៍មូលនិធិពហុភាគីអាចបង្កើតក្រុមជំនាញក្រោមក្រុមការងារនីមួយៗ តាមការចាំបាច់ ។

**ប្រការ ៤.-**

ក្រុមការងារនីមួយៗមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៥.-**

ក្រុមការងារនីតិកម្ម និងបញ្ហាអន្តរវិស័យ មានភារកិច្ចដូចតទៅ:

ក) ផ្ទៀងផ្ទាត់ធនធានដែលមានស្រាប់ និងធនធានទទួលបានពីដៃគូអភិវឌ្ឍន៍នានា ជាមួយគម្រោងអាទិភាពដែលបានកំណត់ និងដែលបានឯកភាពរួច។

ខ) រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយមានកម្មវិធីការងារលំអិត និងសូចនាករសម្រាប់ត្រួតពិនិត្យប្រចាំឆ្នាំលើវិស័យ ដូចខាងក្រោម :

- កំណែទម្រង់ច្បាប់ពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម
- ការសម្រួលពាណិជ្ជកម្ម
- ស្តង់ដារ ការវេចខ្ចប់ របាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម និងល័ក្ខខ័ណ្ឌអនាម័យ និងភូតគាមអនាម័យ
- ការងារកម្មសិទ្ធិបញ្ញា
- ការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងការកែលំអបរិយាកាសវិនិយោគ។

គ) គិតគូរអំពីថ្លៃដែលត្រូវបង់ទៅលើការកែទម្រង់ និងកែសម្រួលរចនាសម្ព័ន្ធ ដែលតម្រូវឱ្យអនុវត្តកាតព្វកិច្ចជាសមាជិកអង្គការតំបន់ និងពិភពលោករបស់កម្ពុជា។

ឃ) ធ្វើកិច្ចការផ្សេងទៀត តាមការប្រគល់ដោយគណៈកម្មការអនុវត្តមូលនិធិពហុភាគី។

**ប្រការ ៦.-**

ក្រុមការងារអភិវឌ្ឍន៍សេវាកម្ម និងផលិតផលសម្រាប់ការនាំចេញ មានភារកិច្ចដូចតទៅ:

ក) ផ្ទៀងផ្ទាត់ធនធានដែលមានស្រាប់ និងធនធានដែលទទួលបានពីដៃគូអភិវឌ្ឍន៍នានា ជាមួយគម្រោងអាទិភាពដែលបានកំណត់ និងដែលបានឯកភាពរួច។

ខ) រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយមានកម្មវិធីការងារលំអិត និងសូចនាករសម្រាប់ត្រួតពិនិត្យប្រចាំឆ្នាំលើវិស័យ ដូចខាងក្រោម :

- បង្កើតផែនការសកម្មភាព និងរៀបចំវិធានការលើកកំពស់សមត្ថភាពផ្គត់ផ្គង់ដល់វិស័យអាទិភាព និងវិស័យផ្សេងទៀតតាមតម្រូវការរបស់វិស័យឯកជន និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- លើកសំណើ និងផ្តល់ដំណោះស្រាយ ដើម្បីគាំទ្រដល់វិស័យដែលបានជ្រើសរើសហើយ ព្រមទាំងកំណត់អាទិភាពវិស័យនីមួយៗ ឱ្យបានច្បាស់លាស់
- ពង្រឹងសមាគមពាណិជ្ជកម្ម និងបង្កើនតម្លៃបន្ថែមផលិតផលព្រមទាំងកសាងសមត្ថភាពលើការធ្វើតេស្តផលិតផលសម្រាប់នាំចេញ និងធានាសុវត្ថិភាពផលិតផលម្ហូបអាហារ
- បង្កើតកម្មវិធីកសាងសមត្ថភាព ស្ថាប័នរដ្ឋនៅមូលដ្ឋាន និងផលិតករអំពីបទដ្ឋានអនាម័យ និងភូតគាមអនាម័យ
- ផ្តល់ការគាំទ្រ និងលើកកំពស់ការអភិវឌ្ឍអាជីវកម្ម និងភាពជាម្ចាស់របស់សហគ្រិន ដើម្បីបង្កើនសមត្ថភាពនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា

- បង្កើតកម្មវិធី និងលើកសំណើ ដើម្បីកសាងក្របខ័ណ្ឌច្បាប់ និងប្រព័ន្ធផ្តល់ឥណទាន ដើម្បីពង្រឹងការផ្តល់ហិរញ្ញប្បទានដល់ការវិនិយោគខ្នាតតូច
- វិភាគវិធានការណ៍ និងស្វែងរកប្រភពធនធាន និងបច្ចេកទេស ដើម្បីជួយអ្នកផលិតនៅថ្នាក់មូលដ្ឋាន
- រៀបចំការងារពាក់ព័ន្ធនឹងការអភិវឌ្ឍសម្រាប់ការនាំចេញផ្សេងទៀត ។

គ) ធ្វើកិច្ចការផ្សេងទៀត តាមការប្រគល់ដោយគណៈកម្មការអនុវត្តមូលនិធិពហុភាគី ។

**ប្រការ ៧.-**

ក្រុមការងារអភិវឌ្ឍន៍សមត្ថភាពពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ :

ក) ផ្ទៀងផ្ទាត់ធនធានដែលមានស្រាប់ និងធនធានទទួលបានពីដៃគូអភិវឌ្ឍន៍នានា ជាមួយគម្រោងអាទិភាពដែលបានកំណត់ និងដែលបានឯកភាពរួច ។

ខ) រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្ស ដែលចាំបាច់សម្រាប់ធានាឱ្យមានកំណើនក្នុងវិស័យពាណិជ្ជកម្ម និងវិស័យពាក់ព័ន្ធនៅកម្ពុជា

គ) រៀបចំកម្មវិធីការងារលំអិត ដែលនឹងត្រូវគាំទ្រដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដោយផ្តោតលើវិស័យសំខាន់ៗ ដូចតទៅ :

- ពង្រឹងសមត្ថភាពមន្ត្រីក្រសួងពាណិជ្ជកម្ម និងមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីគាំទ្រសកម្មភាពពាណិជ្ជកម្មផ្សេងៗ
- ពង្រឹងសមត្ថភាពមន្ត្រីបម្រើការងារនៅក្នុងផ្នែកស្រាវជ្រាវ និងវិភាគពាណិជ្ជកម្ម
- លើកកំពស់ការអភិវឌ្ឍសមត្ថភាពសម្រាប់ការចរចាពាណិជ្ជកម្ម និងការវិនិយោគពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម និងក្រសួង ស្ថាប័នដែលគាំទ្រវិស័យពាណិជ្ជកម្ម ។

ឃ) ធ្វើកិច្ចការផ្សេងទៀត តាមការប្រគល់ដោយគណៈកម្មការអនុវត្តមូលនិធិពហុភាគី ។

**ប្រការ ៨.-**

ប្រធានក្រុមការងារនីមួយៗ ត្រូវរៀបចំរបាយការណ៍ស្តីពីសកម្មភាពនានារបស់ក្រុមការងារសម្រាប់ជូនអង្គប្រជុំនីមួយៗរបស់គណៈកម្មការអនុវត្តមូលនិធិពហុភាគី ។

**ប្រការ ៩.-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃអគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិរបស់ក្រសួងពាណិជ្ជកម្ម ត្រូវបំពេញការងារជាលេខាធិការដ្ឋានគណៈកម្មការអនុវត្តមូលនិធិពហុភាគី ព្រមទាំងធ្វើការងារសម្របសម្រួលជាមួយក្រុមការងារទាំង៣ ។

**ប្រការ ១០.-**

គណៈកម្មការអនុវត្តមូលនិធិពហុភាគី មានសិទ្ធិប្រើត្រារបស់ក្រសួងពាណិជ្ជកម្ម និងមានកញ្ចប់ថវិកាជាឧបសម្ព័ន្ធថវិការបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ១១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ ១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ៨ ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ១២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*